# ផលប៉ះពាល់នៃកូវីដ-១៩ ទៅលើនិយោជិក

## អនុក្រមនៃលទ្ធផលសង្ខេប[1] ទិន្នន័យជុំទី១ ខែខូសតា ឆ្នាំ២០២០


ដោយ ក្រុមហ៊ុនអង្គរស្រាវជ្រាវ និង វេទិកាអនាគត[2]


ក្រោយពីកិច្ចព្រមព្រៀងសន្តិសញ្ញាទីក្រុងប៉ារីសឆ្នាំ១៩៩១ ការប្លាស់ប្តូរដ៏សំខាន់មួយក្នុងប្រទេស គឺការធ្លាក់ចុះកំលាំងពលកម្មនៅក្នុងវិស័យកសិកម្មដែលបានស្រូបយកកំលាំងពលកម្មជាច្រើនក្នុងប្រទេសជាយូរមកហើយ[3]។ ការធ្លាក់ចុះនេះបណ្តាលមកពីការស្រូបយកពលកម្មក្នុងការធ្វើកសិកម្មខ្នាតធំ ការប្រើប្រាស់គ្រឿងយន្តជំនួសអោយកំលាំងមនុស្ស និងការកើនឡើងនៃសេដ្ឋកិច្ចក្នុងវិស័យផ្សេងៗទៀត[4]។ វិស័យដែលរួមចំណែកជម្រុញសេដ្ឋកិច្ចកម្ពុជាសំខាន់ៗដូចជា សំណង់ ទេសចរណ៍ និងវាយនភ័ណ្ឌ ដែលមិនជាប់ពាក់ព័ន្ធនឹងវិស័យកសិកម្ម គឺជាប្រភពយ៉ាងសំខាន់ក្នុងការផ្តល់ការងារដល់ប្រជាពលរដ្ឋតាំងពីឆ្នាំ២០១២[5]។ ដូច្នេះហើយ ចំនួននិយោជិកឬអ្នកធ្វើការ បានកើនឡើងប្រមាណ ៥0 ភាគរយ។ បើទោះជាមានសញ្ញាណវិជ្ជមាន[6] និងមានភាពធន់ទ្រាំខ្លាំងនៃសេដ្ឋកិច្ចក្តី ការឆ្លងរាលដាលនៃជំងឺ កូវីដ-១៩ ជាសាកល បានធ្វើអោយសេដ្ឋកិច្ចជាតិមិនមានលំនឹងដែលបង្កអោយមានផលប៉ះពាល់ដល់កំណើន និងការអភិវឌ្ឍសេដ្ឋកិច្ចនាពេលបច្ចុប្បន្ន។

ដោយកត់សំគាល់ពីកង្វះខាតពត៌មាននៅថ្នាក់ក្រោម ដើម្បីផ្តល់ជាជំនួយដល់ការធ្វើគោលនយោបាយឆ្លើយតបនឹងការឆ្លងរាលដាលនៃជំងឺនេះ ក្រុមហ៊ុនអង្គរស្រាវជ្រាវនិងផ្តល់ប្រឹក្សា សហការណ៍ជាមួយវេទិការអនាគត បានផ្តួចផ្តើមការសិក្សាពីផលប៉ះពាល់សេដ្ឋកិច្ចបណ្តាលមកពីកូវីដ-១៩[7] និងការពិក្សាគោលនយោបាយលើការឆ្លងរាលដាលនៃជំងឺនេះ។ គោលបំណងនៃការសិក្សាគឺការជ្រើសយកសំណាកគ្រួសារក្នុងប្រទេសដោយចៃដន្យដើម្បីកំណត់និងវាយតម្លៃផលប៉ះពាល់សេដ្ឋកិច្ចបណ្តាលមកពីកូវីដ-១៩។ **អនុក្រមនៃលទ្ធផលសង្ខេបនេះនឹងផ្តល់ឱកាសដល់អ្នកពាក់ព័ន្ធក្នុងការធ្វើគោលនយោបាយ ដើម្បីស្វែងយល់ពីលទ្ធផលនៃការស្រាវជ្រាវដែលទទួលបានពីការប្រមូលពត៌មាននៃជុំនិមួយៗរបស់គម្រោងស្រាវជ្រាវនេះ។** ផ្នែកបន្ទាប់នៃរបាយការណ៍សង្ខេបនេះនឹងបង្ហាញពីលទ្ធផលនៃផលប៉ះពាល់លើនិយោជិកឬអ្នកធ្វើការអោយគេ។

### ១. ប្រភេទការងារ និងទីតាំង

តារាងទី១ បង្ហាញអំពីប្រភេទនៃការងារទៅតាមមុខងារនិមួយៗ ដែលទិន្នន័យនេះបង្ហាញយ៉ាងច្បាស់អំពីប្រភេទការងាររបស់អ្នកឆ្លើយតបការអង្កេតបានប្រមូលផ្តុំទៅក្នុងសរសរស្តម្ភសេដ្ឋកិច្ចទាំងបួនដូចដែលបានរៀបរាប់ខាងលើ។

---

[1] ការសិក្សានេះត្រូវបាន ផ្តួចផ្តើម តាក់តែង និងអនុវត្តដោយក្រុមហ៊ុនអអង្គរស្រាវជ្រាវ និងផ្តល់ប្រឹក្សា ការវិភាគនិងការសរសេររបាយការណ៍គឺធ្វើឡើងក្នុងកិច្ចជាដៃគូរគម្រោងជាមួយវេទិការអនាគត។


[2] ការសិក្សានេះគាំទ្រដោយ រដ្ឋាភិបាលអូស្រ្តាលីតាមរយៈនាយកដ្ឋានទំនាក់ទំនងអន្តរជាតិនិងពាណិជ្ជកម្ម ជាមួយនឹង The Asia Foundation។ ការបង្ហាញក្នុងការសិក្សានេះគឺជាមតិយោលបល់ផ្ទាល់របស់អ្នកនិពន្ធ ដែលមិនជាប់ពាក់ព័ន្ធជាមួយនឹង រដ្ឋាភិបាលអូស្រ្តាលី និង The Asia Foundation ឡើយ។


[3] ការងារក្នុងកសិកម្មមានប្រមាណ 80 ភាគរយនៃការងារសរុបក្នុងឆ្នាំ ១៩៨៣។ នៅឆ្នាំ ២០១៩ មានប្រមាណ 32.3 ភាគរយ (World Bank, 2019)។

[4] មើល https://opendevelopmentcambodia.net/topics/labor/ សំរាប់ពត៌មានបន្ថែម។

[5] World Bank (2018)។

[6] បច្ចុប្បន្ន កម្ពុជាមានអត្រាពលកម្មខ្ពស់ជាងគេនៅតំបន់អាស៊ីអាគ្នេយ៍ (82.7 ភាគរយ យោងតាមរបាយការណ៍ 2018 ILO report និងមានអត្រាប្រជាជនដែលគ្រប់អាយុធ្វើការកើនច្រើនជាងអត្រាកំណើនរបស់ប្រជាជនទាំងមូល (growing faster than its total population)។ ស្ថិតិនេះស្របទៅតាមអត្រគ្មានការងារទាបនៅក្នុងប្រទេស (ជាទូទៅទាបជាង 1 ភាគរយ (ILO, 2018)) ហើយវាជាសញ្ញាណវិជ្ជមាននៃកំណើនសេដ្ឋកិច្ចជាតិ។

[7] ប្រើប្រាស់វិធីសាស្រ្តជ្រើសសំណាកតាមក្រុម។ សំណាកបែងចែកជាក្រុមតាមកំរិតខេត្ត ស្រុក និងភូមិ។ ការអង្កេតនឹងត្រូវធ្វើឡើងជាបន្តបន្ទាប់ (longitudinal study) ដែលផ្តោតទៅលើនិយោជិក គ្រួសារដែលមានជំនួយខ្នាតតូច និងកសិករ ក្នុងខេត្តកំពត កំពង់ស្ពឺ ស្វាយរៀង សៀមរាប និងរាជធានីភ្នំពេញ។ សំរាប់ពត៌មានបន្ថែមអំពីការជ្រើសរើសសំណាក និងវិធីសាស្រ្តជ្រើសរើសសូមទាក់ទងមកលោក Ian Ramage តាមរយៈ ian@angkorresearch.com។

**តារាងទី១៖ ប្រភេទការងាររបស់និយោជិក**

| ប្រភេទការងារ | ចំនួន | ភាគរយ |
|---|---|---|
| កម្មករ/កម្មការនី រោងចក្រ | 629 | 37.6 |
| កម្មករ/កម្មការនី សំណង់ | 273 | 16.3 |
| អ្នកស៊ីឈ្នួលធ្វើកសិកម្ម | 106 | 6.3 |
| អ្នកធ្វើការក្នុងវិស័យបដិសណ្ឋារកិច្ច និងសេវាចំណីអាហារ | 93 | 5.6 |
| បុគ្គលិកក្រុមហ៊ុនឯកជន | 73 | 4.4 |
| អ្នកធ្វើការក្នុងវិស័យសេវាកំសាន្តនិងរកស៊ីផ្លូវភេទ | 64 | 3.8 |
| គ្រូបង្រៀន | 62 | 3.7 |
| អ្នកបើកបររថយន្តឈ្នួល | 56 | 3.3 |
| ប៉ូលីស ទាហាន | 49 | 2.9 |
| បុគ្គលិកសាធារណៈ (ក្នុងក្រសួង មេឃុំ មេភូមិជាដើម) | 41 | 2.4 |
| ផ្សេងៗ[8] | 229 | 13.8 |

ភាគច្រើនក្នុងចំណោមនិយោជិកទាំងអស់បានបញ្ជាក់ថាពួកគេធ្វើការក្នុងខេត្តដែលគេរស់នៅ (27.5%) លើកលែងខេត្តកំពត។ ពាក់កណ្តាលនៃនិយោជិកក្នុងខេត្តកំពត (53.4%) គឺធ្វើការក្នុងខេត្តផ្សេង។ តំបន់សំខាន់ៗដែលនិយោជិកចំណាកស្រុកមកធ្វើការគឺ រាជធានីភ្នំពេញ (36%) ក្រុងព្រះសីហនុ (29%) ខេត្តកណ្តាល (9%) និងប្រទេសថៃ (7%)។ ទីតាំងលំអិតដែលប្រមូលផ្តុំនិយោជិកមកធ្វើការបានបង្ហាញក្នុងតារាងទី២ ខាងក្រោម។

**តារាងទី២៖ ទីតាំងការងាររបស់និយោជិក (ប្រៀបនឹងស្រុកកំណើត)**

| ខេត្ត/ក្រុង | ភ្នំពេញ | | សៀមរាប | | កំពត | | ស្វាយរៀង | | កំពង់ស្ពឺ | | សរុប | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | # | % | # | % | # | % | # | % | # | % | # | % |
| ធ្វើការក្នុងភូមិ | 42 | 10.9 | 92 | 34.6 | 53 | 16.5 | 17 | 5.4 | 32 | 8.3 | 236 | 14.1 |
| ធ្វើការក្នុងឃុំ | 44 | 11.4 | 65 | 24.4 | 27 | 8.4 | 19 | 6.1 | 38 | 9.8 | 193 | 11.5 |
| ធ្វើការក្នុងស្រុក | 155 | 40.1 | 41 | 15.4 | 40 | 12.4 | 129 | 41.1 | 84 | 21.8 | 449 | 26.8 |
| ធ្វើការក្នុងខេត្ត | 125 | 32.3 | 38 | 14.3 | 21 | 6.5 | 102 | 32.5 | 174 | 45.1 | 460 | 27.5 |
| ធ្វើការក្នុងខេត្តផ្សេង | 20 | 5.2 | 16 | 6 | 172 | 53.4 | 44 | 14 | 58 | 15 | 310 | 18.5 |
| ធ្វើការនៅក្រៅប្រទេស | 1 | 0.3 | 14 | 5.3 | 9 | 2.8 | 3 | 1 | 0 | 0 | 27 | 1.6 |
| សរុប | 387 | 100 | 266 | 100 | 322 | 100 | 314 | 100 | 386 | 100 | 1675 | 100 |

[8] ផ្សេងៗ រួមបញ្ចូលការងារមួយចំនួនដូចជា សន្តិសុខ អ្នកបកប្រែ និងជាងជួសជុលម៉ូតូ។

### ២. ផលប៉ះពាល់នៃកូវីដ-១៩ លើប្រាក់ខែនិយោជិក

ក្រាហ្វិកទី១ បង្ហាញអំពីប្រាក់ចំណូលក្នុងខែមករា និងមេសា ឆ្នាំ២០២០។ ជាមធ្យម ប្រាក់ខែរបស់និយោជិកបានធ្លាក់ចុះជាខ្លាំងក្នុងកំឡុងខែទាំពីរ។ ប្រាក់ខែជាមធ្យមក្នុងខែមករាគឺ 237.4 ដុល្លាក្នុងមួយខែ ចំណែកនៅខែមេសាប្រាក់ខែរបស់ពួកគេធ្លាក់ចុះមកប្រមាណ 30 ភាគរយ មកត្រឹម 167.2 ដុល្លាក្នុងមួយខែ។ លទ្ធផលមួយគួរអោយកត់សំគាល់ផងដែរគឺចំនួននិយោជិកដែលមិនមានប្រាក់ខែបានកើនឡើងពី 4 ភាគរយក្នុងខែមករា ដល់ 25 ភាគរយក្នុងខែមេសា។ ការកើនឡើងនេះអាចជាមូលហេតុមួយផ្នែកបណ្តាលមកពីការបាត់ចំណូលនៃប្រភេទការងារដែលទទួលបានប្រាក់ចំណូលខ្ពស់បណ្តាលមកការបិទឬផ្អាកអាជីវកម្មមួយចំនួន។

**ក្រាហ្វិកទី១៖ ផលប៉ះពាល់នៃកូវីដ-១៩ ទៅលើប្រាក់ខែនិយោជិក (ប្រធៀបរវាងខែមករា និងមេសា ឆ្នាំ២០២០)**




នៅពេលយើងពិនិត្យលំអិតទៅលើភាពខុសគ្នានៃផលប៉ះពាល់ទៅលើប្រភេទនិយោជិកផ្លូវការ (មានកុងត្រា) និងមិនផ្លូវការ (មិនមានកុងត្រា) យើងអាចសង្កេតឃើញថាប្រភេទការងារមិនមានកុងត្រាទទួលបានប្រាក់ខែទាបជាងនិយោជិកដែលមានកុងត្រា ហើយនិយោជិកដែលមិនមានកុងត្រាក៏ធ្លាក់ចុះប្រាក់ខែ 8 ភាគរយច្រើនជាងនិយោជិកដែលមានកុងត្រាផងដែរ ក្នុងកំឡុងខែមករា និងមេសា (មើលក្រាហ្វិកទី២)។

**ក្រាហ្វិកទី២៖ ប្រៀបធៀបផលប៉ះពាល់ដោយកូវីដ-១៩ ទៅលើនិយោជិកមានកុងត្រា និងមិនមានកុងត្រា**



ក្រាហ្វិកទី៣ បង្ហាញពីផលប៉ះពាល់លើប្រាក់ចំណូលទៅតាមកំរិតវប្បធម៌របស់និយោជិក។ លទ្ធផលបានបង្ហាញយ៉ាងច្បាស់ថា និយោជិកដែលមានកំរិតវប្បធម៌ទាបបានបាត់បង់ចំណូលច្រើនជាង។ ចំពោះនិយោជិកដែលមានសញ្ញាបត្របរិញ្ញាបានថយចុះប្រាក់ចំណូលប្រមាណ 6.5 ភាគរយ ទិន្នន័យនេះមានភាគរយទាបបើប្រៀបនឹង និយោជិកដែលមានការសិក្សាកំរិតវិទ្យាល័យ (20 ភាគរយ) ថ្នាក់បឋមសិក្សា (30 ភាគរយ) និងអ្នកមិនបានទទួលការអប់រំជាផ្លូវការ (32 ភាគរយ) ហើយអ្នកដែលទទួលបានការអប់រំតាមវត្តអារាមបានធ្លាក់ចុះចំណូលដល់ទៅ 42 ភាគរយ។

**ក្រាហ្វិកទី៣៖ ផលប៉ះពាល់ប្រាក់ចំណូលរបស់និយោជិកតាមកំរិតវប្បធម៌**




ផលប៉ះពាល់របស់កូវីដ-១៩ ទៅលើនិយោជិកក៏មានភាពខុសគ្នាទៅតាមទីតាំងភូមិសាស្ត្រផងដែរ (ក្រាហ្វិកទី៤)។ នៅខេត្តកំពត ប្រាក់ឈ្នួលរបស់និយោជិកធ្លាក់ចុះ 39 ភាគរយគិតត្រឹមខែមេសា តាមពីក្រោយដោយខេត្តសៀមរាប ស្វាយរៀង និងកំពង់ស្ពឺ ដែលធ្លាក់ចុះប្រមាណ 31 ភាគរយដូចៗគ្នា និងនៅរាជធានីភ្នំពេញធ្លាក់ចុះ 23 ភាគរយ។ ការធ្លាក់ចុះប្រាក់ចំណូលខ្លាំងនៅក្នុងខេត្តកំពតអាចបណ្តាលមកពីប្រភេទការងារដែលពួកគេធ្វើគឺការងារសំណង់ដែលជាទូទៅជាប្រភេទការងារមិនផ្លូវការ (94.5 ភាគរយ មិនមានកុងត្រា) នេះបើប្រៀបធៀបជាមួយនិយោជិកនៅភ្នំពេញដែល ២ ភាគ ៣ នៃពួកគេគឺជានិយោជិកដែលមានកុងត្រា។

**ក្រាហ្វិកទី៤៖ ផលប៉ះពាល់នៃកូវីដ-១៩ ទៅលើនិយោជិកតាមតំបន់សិក្សា**



បើពិនិត្យទៅលើផលប៉ះពាល់ទៅតាមប្រភេទការងារវិញ យើងឃើញថាអ្នកដែលបំពេញការងារក្នុងវិស័យសេវាកំសាន្តនិងរកស៊ីផ្លូវភេទ ត្រូវបានរកឃើញថាបានធ្លាក់ចុះប្រាក់ចំណូលច្រើនជាងគេ (84.5 ភាគរយ) បន្ទាប់មកគឺបុគ្គលិកផ្នែកសេវានិងបដិសណ្ឋារកិច្ច (56.4 ភាគរយ) ផ្នែកសំណង់ (36.8 ភាគរយ) វិស័យរោងចក្រ (29.8 percent) និងអ្នកស៊ីឈ្នួលក្នុងវិស័យកសិកម្ម (25 ភាគរយ)។

**ក្រាហ្វិកទី៥៖ ផលប៉ះពាល់នៃកូវីដ-១៩ ទៅលើនិយោជិកតាមប្រភេទការងារ**




### ៣. សង្ខេបនៃលទ្ធផល

លទ្ធផលនៃការប្រមូលទិន្នន័យជុំទី១ បានបង្ហាញថានិយោជិកគ្រប់វិស័យទាំងអស់រងផលប៉ះពាល់អវិជ្ជមានពីការឆ្លងរាលដាលនៃជំងឺកូវីដ-១៩។ ជាមធ្យមប្រាក់ខែរបស់ពួកគេធ្លាក់ចុះប្រមាណ 30 ភាគរយ ចន្លោះខែមករា និងខែមេសា ឆ្នាំ២០២០។ ជាការកំណត់សំគាល់មួយសំរាប់អ្នកតាក់តែងគោលនយោបាយ លទ្ធផលបង្ហាញថា និយោជិកម្នាក់ក្នុងចំណោម៤នាក់បញ្ជាក់ថាពួកគេមិនទទួលបានប្រាក់ខែក្នុងខែមេសា ដែលតួលេខនេះកើនពី ម្នាក់ក្នុងចំណោម២៥នាក់ នៅក្នុងខែមករា។

លើសពីនេះទៅទៀត ផលប៉ះពាល់មិនមានភាពស្មើគ្នាទៅលើគ្រប់ប្រភេទនិយោជិកទេ។ និយោជិកដែលមិនមានកុងត្រាការងារទទួលបានប្រាក់ឈ្នួលទាបជាងនិយោជិកដែលមានកុងត្រាការងារតាំងតែមុនពេលឆ្លងរាលដាលនៃជំងឺ ហើយគម្លាតនេះគឺវាកាន់តែកើនឡើងចន្លោះពេលខែមករា និងខែមេសា។ ស្រដៀងគ្នានេះដែរ និយោជិកដែលមិនមាន ឬមានកំរិតវប្បធម៌ទាបរងការធ្លាក់ចុះប្រាក់បៀវត្សខ្លាំងបើប្រៀបនឹងនិយោជិកដែលមានកំរិតវប្បធម៌ខ្ពស់។

លទ្ធផលក៏បង្ហាញពីភាពខុសគ្នាខ្លាំងបើយើងពិនិត្យទៅតាមតំបន់សិក្សាក៏ដូចជាវិស័យនៃប្រភេទការងារផងដែរ។ និយោជិកដែលនៅតាមខេត្តជាទូទៅរងការធ្លាក់ចុះប្រាក់បៀវត្សច្រើនជាងអ្នកដែលនៅរាជធានីភ្នំពេញ។ ជាចុងក្រោយ និយោជិកនៅក្នុងវិស័យកសិកម្មបានធ្លាក់ចុះប្រាក់ពលកម្មតែ 25 ភាគរយប៉ុណ្ណោះ នេះបើប្រៀបធៀបនឹងអ្នកដែលធ្វើការក្នុងវិស័យសេវាកំសាន្តនិងរកស៊ីផ្លូវភេទដែលបញ្ជាក់ប្រាប់ថាពួកគេធ្លាក់ចុះចំណូលដល់ទៅ 85 ភាគរយ។